គ.ជ.ប

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

8

# ខិត្តប័ណ្ណស្តីពី

## សារៈសំខាន់នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៨

- ជាករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបោះឆ្នោតគ្រប់រូបដែលត្រូវតែទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។
- ផ្តល់ឱកាសជូនប្រជាពលរដ្ឋគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោតរួចហើយ ទៅពិនិត្យមើលឈ្មោះរបស់ខ្លួនឱ្យប្រាកដថា មាននៅក្នុងបញ្ជីបោះឆ្នោតពិតប្រាកដ ។
- សម្អាតបញ្ជីបោះឆ្នោតប្រចាំឆ្នាំអោយមានភាពសុក្រឹត ដោយលុបឈ្មោះអ្នកស្លាប់-អ្នកបាត់បង់សិទ្ធិបោះឆ្នោត-អ្នកមានឈ្មោះស្ទួន-អ្នកផ្លាស់ប្តូរទីលំនៅចេញទៅ ឃុំ សង្កាត់ ផ្សេង និងអ្នកដែលពុំមានសិទ្ធិបោះឆ្នោត ។
- ផ្តល់ឱកាសជូនប្រជាពលរដ្ឋខ្មែរដែលផ្លាស់ទីលំនៅចូលក្នុងឃុំ សង្កាត់ថ្មី-អ្នកពុំធ្លាប់បានចុះឈ្មោះបោះឆ្នោត-អ្នកពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត-អ្នកគ្រប់អាយុ ១៨ឆ្នាំ គិតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ បានចុះឈ្មោះបោះឆ្នោត ។
- ផ្តល់ឱកាសជូនប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានមិនត្រឹមត្រូវតាមឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ដើម្បីសុំធ្វើការកែតម្រូវវិញឱ្យបានត្រឹមត្រូវ ។
- ផ្តល់ឱកាសជូនប្រជាពលរដ្ឋខ្មែរ ប្តឹងតវ៉ាទៅនឹងការបាត់ឈ្មោះ ការខុសឈ្មោះ និងទិន្នន័យផ្សេងៗ ឬ/និងប្តឹងជំទាស់ទៅនឹងអ្នកដែលគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោត និងអ្នកមានឈ្មោះលើសពីមួយក្នុងបញ្ជីបោះឆ្នោត ។

## លក្ខខណ្ឌ ៤យ៉ាង សម្រាប់ការសុំចុះឈ្មោះបោះឆ្នោត ½

១- ត្រូវមានឯកសារបញ្ជាក់អត្តសញ្ញាណ ។

២- ត្រូវមានសញ្ជាតិខ្មែរ ។

៣- ត្រូវមានអាយុ ១៨ ឆ្នាំ ឡើងទៅ គិតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ។

៤- ត្រូវមានទីលំនៅក្នុង ឃុំ សង្កាត់ ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត ។

សាមីខ្លួនត្រូវទៅសុំចុះឈ្មោះដោយផ្ទាល់ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមសាលាឃុំ សង្កាត់ ឬនៅទីតាំងណាមួយក្នុងឃុំ សង្កាត់ ដែលបងប្អូនកំពុងរស់នៅ ។

## កាលបរិច្ឆេទនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

## ចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៨